# លទ្ធផលនៃការស្ទង់មតិប្រជាពលរដ្ឋស្តីពីគ្រឿងស្រវឹង

ការស្ទង់មតិនេះ ធ្វើឡើងនៅចុងឆ្នាំ២០១៤ ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្រោមការគាំទ្ររបស់អង្គការសុខភាពពិភពលោក អង្គការចលនាដើម្បីសុខភាពកម្ពុជា និងដៃគូសុវត្ថិភាពចរាចរណ៍ផ្លូវគោកសកល។ ខាងក្រោមនេះជាលទ្ធផលនៃការស្ទង់មតិ៖

## ១ ការប្រើប្រាស់គ្រឿងស្រវឹង

ប្រជាពលរដ្ឋពេញវ័យកម្ពុជាលើសពី៥០%ធ្លាប់ទទួលទានគ្រឿងស្រវឹងក្នុងអំឡុងពេល១២ខែចុងក្រោយនេះ បើបែងចែកតាមភេទគឺ បុរស៧៣% និងស្ត្រី២៣%។




ក្រាបបង្ហាញពីការប្រើប្រាស់គ្រឿងស្រវឹង បែងចែកតាមភេទ

ស្ថានភាពនៃការបប្រើប្រាស់គ្រឿងស្រវឹងរបស់យុវជនកម្ពុជា



ប្រជាពលរដ្ឋកម្ពុជាភាគច្រើនចាប់ផ្តើមប្រើប្រាស់គ្រឿងស្រវឹងក្នុងវ័យយុវជន និងកុមារ (៩១%)។

ស្រាបៀរគឺជាប្រភេទគ្រឿងស្រវឹងដែលប្រជាពលរដ្ឋកម្ពុជានិយមសេពរហូតដល់ ៨៤%។ ប្រជាពលរដ្ឋកម្ពុជាទទួលឥទ្ធិពលពីការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងក្នុងការជ្រើសរើសម៉ាកគ្រឿងស្រវឹង ក្នុងនោះ ៣៨%ដោយសាររសជាតិឆ្ងាញ់ ២៨%ដោយសារម៉ាកល្បី ១៦%ដោយសារតម្លៃថោក និង១១%ដោយសារចង់ត្រូវរង្វាន់។ ហេតុផលទាំងនេះសុទ្ធតែជាសារទាក់ទាញដែលគេប្រើក្នុងការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង។

## សារដែលគេប្រើក្នុងការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង




ផ្ទាំងរូបភាពផ្សាយពីតម្លៃស្រាបៀរ




ផ្ទាំងរូបភាពផ្សាយពីរសជាតិ




រូបភាពផ្សាយពីគុណភាព

# ប្រជាពលរដ្ឋភាគច្រើនទិញគ្រឿងស្រវឹងពីផ្ទះឬតូបលក់គ្រឿងទេសសម្រាប់សេព។




ក្រាបបង្ហាញពីទីកន្លែងដែលប្រជាពលរដ្ឋទិញគ្រឿងស្រវឹងប្រើប្រាស់



តូបលក់គ្រឿងទេសមានដាក់លក់គ្រឿងស្រវឹងយ៉ាងព្រោងព្រាត



រាជរដ្ឋាភិបាលគួរកំណត់ទីតាំងលក់គ្រឿងស្រវឹងឲ្យបានសមស្របដើម្បីកាត់បន្ថយលទ្ធភាពងាយរកទិញគ្រឿងស្រវឹង។ កន្លែងលក់គ្រឿងស្រវឹងគួរតែមានអាជ្ញាប័ណ្ណអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច។

## ២ ទស្សនៈអំពីការប្រើប្រាស់គ្រឿងស្រវឹង

ប្រជាពលរដ្ឋកម្ពុជាស្ទើរតែទាំងអស់យល់ថាការប្រើប្រាស់គ្រឿងស្រវឹងបណ្តាលឲ្យមានបញ្ហាអវិជ្ជមាន។



៩៩%យល់ថាពាក់ព័ន្ធនឹងអំពើហិង្សា



៩៩%យល់ថាបង្កឲ្យមានគ្រោះថ្នាក់ចរាចរណ៍



៩៨%យល់ថាប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ



ជម្ងឺក្រិនថ្លើមបណ្តាលមកពីគ្រឿងស្រវឹង

៩៩%យល់ថាបង្កជម្ងឺ

## ផលប៉ះពាល់នៃគ្រឿងស្រវឹង

- គ្រឿងស្រវឹងគឺជាមូលហេតុទី៣ដែលបណ្តាលឲ្យមានអ្នកស្លាប់នៅលើពិភពលោកប្រមាណ ២.៥លាននាក់ក្នុង១ឆ្នាំៗ[១] និងបង្កឲ្យមានជម្ងឺប្រមាណ២០០មុខ រួមមានជម្ងឺមហារីកបំពង់អាហារ មហារីកថ្លើម ជម្ងឺលើសសំពាធឈាម ជម្ងឺស្ទះសរសៃឈាមបេះដូង ខួរក្បាល ជម្ងឺក្រិនថ្លើម រលាកលំពែង វិកលវិបល្លាសជាដើម[២]។ ក្រៅពីនេះគ្រឿងស្រវឹងក៏ជាដើមហេតុនៃគ្រោះថ្នាក់ចរាចរណ៍ ការបាត់បង់សណ្តាប់ធ្នាប់សង្គម អំពើហិង្សាក្នុងគ្រួសារ និងបញ្ហាសង្គមជាច្រើនទៀត។

- នៅកម្ពុជាគ្រឿងស្រវឹងជាមូលហេតុចម្បងទី២ដែលបណ្តាលឲ្យគ្រោះថ្នាក់ចរាចរណ៍។ កម្ពុជាខាតបង់ថវិកាប្រមាណ៤៤លានដុល្លារអាមេរិកជារៀងរាល់ឆ្នាំដោយសារគ្រោះថ្នាក់ចរាចរណ៍ដែលបណ្តាលមកពីការបើកបរក្រោមឥទ្ធិពលគ្រឿងស្រវឹង[៣]។

- ៩០%នៃកុមារកម្ពុជាដែលមានអាយុចន្លោះពី ១០-១២ឆ្នាំបានឆ្លើយថាគ្រឿងស្រវឹងជាមូលហេតុចម្បងដែលធ្វើឲ្យមានអំពើហិង្សាក្នុងគ្រួសារនិងសហគមន៍[៤]។ ស្ទើរតែគ្រប់ប្រភេទនៃអំពើហិង្សាក្នុងគ្រួសារមានកើនឡើងស្របគ្នានឹងភាពញឹកញាប់នៃការផឹកគ្រឿងស្រវឹងរបស់ប្តី/ប្រពន្ធ។ ជាក់ស្តែង បើមានការសេពគ្រឿងស្រវឹងស្ទើរតែរៀងរាល់ថ្ងៃនោះអំពើហិង្សាដោយការជេរប្រមាថកើនឡើង៣០% បើធៀបនឹងការមិនសេពគ្រឿងស្រវឹង[៥]។

---

១ World Health Organization, Global Report on Alcohol and Health 2011
២ Institute of Health Matrix and Evaluation, 2012
៣ Handicap International, Analysis of 2011 Road Crash Cost in Cambodia
៤ Small voices, Big dreams survey by Child Fund 2013
៥ Violence against women, 2009 follow up survey

## ៣ ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង

ប្រជាពលរដ្ឋកម្ពុជា៩៨% បានជួបប្រទះការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងក្នុងរយៈពេល៣០ថ្ងៃចុងក្រោយ តាមទម្រង់ផ្សេងៗ។




ក្រាបបង្ហាញពីទម្រង់នៃការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង
ដែលប្រជាពលរដ្ឋប្រទះឃើញ

ក្នុងនោះប្រជាពលរដ្ឋ៩២%យល់ថា ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹងជាកត្តាចម្បងនាំឲ្យកុមារនិងយុវជនចាប់ផ្ដើមប្រើប្រាស់គ្រឿងស្រវឹង។



**ប្រជាពលរដ្ឋកម្ពុជា ៩៣% ចង់ឲ្យរាជរដ្ឋាភិបាលហាមឃាត់ការផ្សាយពាណិជ្ជកម្មគ្រឿងស្រវឹង។**



ផ្ទាំងប៉ាណូដាក់តាមបណ្ដោយផ្លូវ២៧១


នារីស្អាតៗផ្សព្វផ្សាយស្រាបៀរ



ការផ្សាយពាណិជ្ជកម្មតាមការប្រគុំតន្ត្រី

# ៤ ពន្ធលើគ្រឿងស្រវឹង

ការដំឡើងពន្ធលើផលិតផលគ្រឿងស្រវឹងមានឥទ្ធិពលលើការប្រើប្រាស់គ្រឿងស្រវឹងរបស់ប្រជាពលរដ្ឋកម្ពុជា។




ក្រាបបង្ហាញពីឥទ្ធិពលនៃការដំឡើងពន្ធផលិតផលគ្រឿងស្រវឹង ទៅលើការប្រើប្រាស់



**ប្រជាពលរដ្ឋកម្ពុជា ៧៥%គាំទ្ររាជរដ្ឋាភិបាលក្នុងការដំឡើងពន្ធលើផលិតផលគ្រឿងស្រវឹង។**

**ការដំឡើងពន្ធលើផលិតផលគ្រឿងស្រវឹងគឺជាយុទ្ធសាស្រ្តសកលដែលមានប្រសិទ្ធភាពបំផុតដើម្បីកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង។**




ប្រភព: World Health Organization, Global Strategy to Reduce Harmful Use of Alcohol, adopded by the 63th session of the World Health Assembly, May 2010

# ៩ គ្រឿងស្រវឹង និងកុមារ

ប្រជាពលរដ្ឋកម្ពុជារហូតដល់៨៧%ដែលបានសង្កេតឃើញកុមារទិញគ្រឿងស្រវឹង ហើយប្រជាពលរដ្ឋ៩៥%សុំឲ្យរាជរដ្ឋាភិបាលហាមឃាត់ការលក់គ្រឿងស្រវឹងឲ្យកុមារ។




ក្មេងៗប្រមូលផ្តុំគ្នាផឹកស្រា

ប្រជាពលរដ្ឋកម្ពុជា៩៦% ស្នើសុំយ៉ាងទទូចដល់រាជរដ្ឋាភិបាលឲ្យចាត់វិធានការដែលមានប្រសិទ្ធភាពបន្ថែមទៀតដើម្បីកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹង។ ក្នុងន័យនេះការអនុម័តច្បាប់ស្តីពីការគ្រប់គ្រងផលិតផលគ្រឿងស្រវឹងគឺជាវិធានការដ៏មានប្រសិទ្ធភាពបំផុត។


World Health Organization

GLOBAL ROAD SAFETY PARTNERSHIP

CMH CAMBODIA MOVEMENT FOR HEALTH